**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០១៨

**សេចក្តីផ្តើម**:

នៅក្នុងខែកញ្ញានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

I.**លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**:

**១.មុខងារនីតិកម្ម**:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - បានថតចម្លងឯកសារចំនួន១២ច្បាប់ អស់ក្រដាសចំនួន១,៣៣៥សន្លឹក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៥នាក់ ស្មើនឹង០១លើក<br>- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរាជធានីភ្នំពេញចំនួន០៥នាក់ ស្មើនឹង០២លើក<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន៣៩ច្បាប់<br>- បានស្រាវជ្រាវ បកប្រែ និងសង្ខេបព័ត៌មាន |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | សភាអន្តរជាតិបានចំនួន១៧៣ច្បាប់<br>- បានចុះត្រួតពិនិត្យប្រព័ន្ធសំឡេង និងកាមេរ៉ាវីដេអូ នៅសាលប្រជុំពេញអង្គ និងសាលប្រជុំគណៈ-កម្មាធិការអចិន្ត្រៃយ៍ចំនួន១៥លើក<br>- បានប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន០២លើក។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញជួបសវនាការការងារជាមួយប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ដើម្បីសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនៅខេត្តកំពត<br>+ អញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់អំពីសភាពការណ៍រួម និងសភាពការណ៍ពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៅខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន<br>+ អញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់អំពីការអនុវត្តសិទ្ធិមនុស្ស និងដោះស្រាយពាក្យបណ្តឹងរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង<br>+ អញ្ជើញចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មានជាមួយថ្នាក់ដឹកនាំស្រុក និងអាជ្ញាធរមូលដ្ឋាន នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម | - បានធ្វើលិខិតបេសកកម្ម ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៥នាក់ ស្មើនឹង០៦ច្បាប់។<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់សមាជិក សមជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៅតាមភូមិភាគទាំង៨ ចំនួន១០លើក។ |

| | |
|---|---|
| + អញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់អំពីការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តសៀមរាប។ | |

**៣.មុខងារតំណាង**:

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា៖<br>+ អញ្ជើញជាកិត្តិយសក្នុងពិធីបើកសម័យប្រជុំដំបូងនៃរដ្ឋសភា នីតិកាលទី៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញជូនព្រះរាជដំណើរព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** យាងទៅកាន់ទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ<br>+ អញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីសច្ចាប្រណិធាន នៅក្នុងព្រះបរមរាជវាំង<br>+ អញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន និងញាតិកាទាំង៧សន្តាន របស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅខេត្តកំពង់ចាម<br>+ អញ្ជើញគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខក្រុមគ្រួសារសព ឯកឧត្តម **កើ ណៃលាង** | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតីក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន២០៨លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងការចុះបេសកកម្មអមដំណើរក្រុមសមាជិកសមាជិកាព្រឹទ្ធសភា អញ្ជើញចុះចែកអំណោយពិភាក្សាការងារ នៅខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្តកណ្តាល<br>- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗចំនួន០៤លើក<br>- បានរៀបចំសម្អាត តុបតែងសាល ផ្គត់ផ្គង់ និងផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗសរុបចំនួន០៩លើក<br>- បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២២នាក់ ស្មើនឹង០៤ច្បាប់<br>- បានថតចម្លងឯកសារចំនួន២៤០ច្បាប់ អស់ក្រដាសចំនួន១,០៦២សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន១២៦នាក់ |

| | |
|---|---|
| ទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា នៅគេហដ្ឋាននៃសព<br>+ អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខជាមួយប្រជាពលរដ្ឋនៅខេត្តកោះកុង ខេត្តប៉ៃលិន ខេត្តក្រចេះ និងខេត្តកំពង់ចាម<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ០៨ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៥ករណី ព្រមទាំងកំពុងពិនិត្យសិក្សាចំនួន០៨ករណី និងធ្វើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន០១ករណី ទទួលឯកសារពាក្យបណ្តឹងពីក្រសួង ស្ថាប័ន ដែលចម្លងជូនមកព្រឹទ្ធសភាជ្រាបចំនួន ០៩ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញទូទាំងប្រទេសចំនួន១៣៣លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ | ស្មើនឹង៥០លើក<br>- បានបញ្ជូនលិខិតចេញចំនួន៣៦ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៨០លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៥៥នាក់ ស្មើនឹង០៨លើក<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០១លើក<br>- បានផ្តល់អត្ថបទព័ត៌មាន និងរូបថតចំនួន ២២៥សន្លឹក ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៣៨នាក់ អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន២២ក្បាល និងសងវិញចំនួន២៩ក្បាល ព្រមទាំងបានធ្វើកាតសមាជិកបណ្ណាល័យជូនសិស្ស និងនិស្សិតចំនួន០៥នាក់<br>- បានទទួលឯកសារ សៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តីចំនួន១៣២ក្បាល កាសែត និងព្រះរាជក្រមចំនួន២២៣ច្បាប់ ពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន វិទ្យាស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានផ្តល់សៀវភៅ និងទស្សនាវដ្តីព្រឹទ្ធសភា ជូនដល់សាកលវិទ្យាល័យបញ្ញាសាស្ត្រចំនួន២៥ក្បាល<br>- បានកំពុងរៀបចំផលិតសៀវភៅនិនានុលេខន៍ប្រតិទិន និងប្រតិទិនផែនការខែ ឆ្នាំ២០១៩<br>- បានបោះពុម្ពសំបុត្រសារព័ត៌មាន(Newsletter) |

| | |
|---|---|
| ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៦៨លើក។ | ស្ដីពី លទ្ធផលការងារក្នុងសម័យប្រជុំលើកទី១ ព្រឹទ្ធសភា នីតិកាលទី៤<br>- បានរៀបចំទស្សនាវដ្ដីប្រចាំខែសីហា ឆ្នាំ២០១៨<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្ដីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន៥២លើក<br>- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន២៧លើក<br>- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សានៅព្រឹទ្ធសភាចំនួន០២លើក របស់គណៈប្រតិភូចិន ក្រុមសមាជិកាព្រឹទ្ធសភា និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន៣៣៣នាក់។ |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ***សម្ដេចប្រមុខរដ្ឋស្ដីទី*** បានទទួលជួបសម្ដែងការគួរសម និងជម្រាបលា ជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតចិន រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិគណៈកម្មាធិការបក្សកុម្មុយនីស្តចិន រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋឥណ្ឌា និងគណៈប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា និងជប៉ុន(SSEAYP) លើកទី៤៥ ឆ្នាំ២០១៨<br>- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា បានទទួលជួបសម្ដែងការគួរសម ជាមួយអនុប្រធានគណៈកម្មាធិការប្រឹក្សានយោបាយចិនប្រចាំខេត្តឡៀនីង នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងឱកាសដែលឯកឧត្តមអញ្ជើញមកបំពេញទស្សនកិច្ចសិក្សានៅកម្ពុជា ព្រមទាំងដឹកនាំ | - ត្រៀមកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) តាមការប្រែប្រួលថ្មី ដែលយកប៉ូលតំបន់ជាឧត្ដមភាព<br>- បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងសម្រាប់ជំនួបសម្ដែងការគួរសម និងជម្រាបលាចំនួន០៥លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន៣៨លើក<br>- បានរៀបចំសម្អាត តុបតែងសាល ផ្គត់ផ្គង់សម្ភារៈអនាម័យ បម្រើសេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងកិច្ចប្រជុំចំនួន១១លើក<br>- បានថតចម្លងឯកសារចំនួន៦៥៦ច្បាប់ អស់ |

| | |
|---|---|
| គណៈប្រតិភូព្រឹទ្ធសភា ចូលរួមប្រជុំមហាសន្និបាតអន្តរសភា(AIPA) លើកទី៣៩ និងចូលរួមក្នុងពិធីជប់លៀងអាហារសាមគ្គីរវាងប្រទេសអាស៊ានទាំង១០ និងអញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយប្រធានាធិបតីនៃសាធារណរដ្ឋសិង្ហបុរី ប្រធានអាយប៉ា និងជាប្រធានសភានៃសាធារណរដ្ឋសិង្ហបុរី និងប្រធានគណៈប្រតិភូសភាវៀតណាម នៅសាធារណរដ្ឋសិង្ហបុរី ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីពិព័រណ៍អន្តរជាតិចិនភាគខាងលិចលើកទី១៧ និងជួបពិភាក្សាការងារជាមួយអភិបាលខេត្ត និងប្រធានគណៈកម្មាធិការរៀបចំពិធីពិព័រណ៍អន្តរជាតិចិនភាគខាងលិចលើកទី១៧ និងជាលេខាធិការរងបក្សកុម្មុយនីស្តចិន នៃខេត្តស៊ីឈួន នៅសាធារណរដ្ឋប្រជាមានិតចិន ព្រមទាំងចូលរួមក្នុងកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) លើកទី១០ នៅប្រទេសបែលហ្ស៊ិក<br>- ឯកឧត្តម ម៉ុង ឫទ្ធី បានអនុញ្ញាតឱ្យក្រុមអ្នកវិនិយោគទុនមកពីព្រះរាជាណាចក្រជប៉ុន និងភ្ញៀវមកពីប្រទេសតៃវ៉ាន ចូលជួបពិភាក្សាការងារ<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមកម្មវិធីបើកវេទិកាEVAL Colombo 2018 នៅប្រទេសស្រីលង្កា ចូលរួមក្នុងវេទិកាស្ត្រីអាស៊ី-អឺរ៉ុបលើកទី២ នៅសហព័ន្ធរុស្ស៊ី ចូលរួមកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) លើកទី១០ នៅប្រទេសបែលហ្ស៊ិក ចូលរួមពិធី | ក្រដាសចំនួន៣,១៥០សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៣៨នាក់ ស្មើនឹង១៨លើក<br>- បានធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូតសំណើ និងលិខិតឆ្លើយតបទៅក្រសួង ស្ថាប័នផ្សេងៗ និងបណ្តាអង្គទូតនានាចំនួន១០លើក<br>- ធ្វើលិខិតទៅក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំជំនួយស្មារតីចំនួន០៤លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២២នាក់ ស្មើនឹង០៤ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅបំពេញបេសកកម្មនៅក្រៅប្រទេស ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន២៧លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១០០នាក់ ស្មើនឹង១២លើក<br>- បានរៀបចំបែបបទជូនគណៈប្រតិភូសមាជិកព្រឹទ្ធសភា អញ្ជើញទៅចូលរួមវេទិកា កិច្ចប្រជុំ និងពិធីផ្សេងៗនៅក្រៅប្រទេសចំនួ០៦លើក<br>- បានរៀបចំបែបបទជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលា នៅក្រៅប្រទេសចំនួន១៥លើក |

| | |
|---|---|
| អបអរសាទរខួប៦០ឆ្នាំនៃទំនាក់ទំនងការទូតចិន និងកម្ពុជា នៅសាធារណរដ្ឋប្រជាមានិតចិន ចូលរួមវេទិកាសភាពិភពលោកលើកទី២ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមប្រធានបទភាពជាដៃគូឆ្ពោះទៅរកថាមពលប្រកបដោយចីរភាពសម្រាប់យើងទាំងអស់គ្នា នៅប្រទេសឥណ្ឌូនេស៊ី ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីលទ្ធផលមហាសន្និបាតនៃសភាប្រើប្រាស់ភាសាបារាំង(APF)លើកទី៤៤ នៅប្រទេសកាណាដា។ | - បានទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន និងបណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅព្រឹត្តិបត្រ និងសម្រួលដល់កិច្ចការអន្តរជាតិ ដំណើរទស្សនកិច្ច សិក្ខាសាលា បេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| | + បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៧៩ច្បាប់<br>- បានរៀបចំធ្វើបទបង្ហាញស្តីពី របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន<br>- រៀបចំចងក្រងសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកញ្ញា និងនព្វមាស ឆ្នាំ២០១៨ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៤០ច្បាប់<br>- បានពិនិត្យវាយតម្លៃការអនុវត្តផែនការប្រតិបត្តិប្រចាំនព្វមាស ឆ្នាំ២០១៨។ |

| | |
|---|---|
| | + **ការងារគ្រប់គ្រងបុគ្គលិកៈ**<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៤១ច្បាប់<br>- ប្រជុំគណៈកម្មការគោលនយោបាយស្តីពី របៀបរបបសុំច្បាប់ និងការអនុញ្ញាតច្បាប់ ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការនៃអគ្គលេខាធិ-ការដ្ឋានព្រឹទ្ធសភា<br>- បានធ្វើបែបបទស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទីភារកិច្ច និងសមត្ថកិច្ចនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានចុះជំរឿនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងអ្នកហាត់ការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានបោះពុម្ពសៀវភៅច្បាប់ស្តីពី ច្បាប់លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ចំនួន១,០០០ក្បាល។<br>+ **ការងារបណ្តុះបណ្តាលធនធានមនុស្សៈ**<br>- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៧វគ្គ មានសិក្ខាកាមសរុបចំនួន៤៣នាក់។<br>+ **ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**<br>- បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ប្រជុំរៀបចំគោលការណ៍ហិរញ្ញវត្ថុសម្រាប់នីតិកាលទី៤ ព្រឹទ្ធសភា<br>- ប្រជុំពិនិត្យលើការអនុវត្តកញ្ចប់ថវិការបស់គណៈ-កម្មការជំនាញ និងក្រុមនានារបស់ព្រឹទ្ធសភា (រចនាសម្ព័ន្ធនយោបាយ) |

| | |
|---|---|
| | - បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្សប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន ១៦សំណើ បានផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៤៧សំណើ សម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំសម្អាត តុបតែងសាលប្រជុំ ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន ១៩លើក មានអ្នកចូលរួមចំនួន៥៦៧នាក់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២១៧លើក<br>- បានថតចម្លងឯកសារចំនួន៧,៤៥៩ច្បាប់ និងចងក្រងសៀវភៅចំនួន៦៦ក្បាល អស់ក្រដាសចំនួន២៦,៣៥៣សន្លឹក និងលាងសម្អាតម៉ាស៊ីនថតចម្លង និងម៉ាស៊ីនព្រីនធ័រចំនួន១៦លើក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានីភ្នំពេញចំនួន ១៦នាក់ ស្មើនឹង១២លើកៗ |

+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់ :

- កសាងអគារថ្មី០១ខ្នង សម្រាប់វិទ្យាស្ថានសភាកម្ពុជា(PIC)
- បានពង្រីកអគារបណ្ណាល័យបន្ថែម ដើម្បីផ្ទុកឯកសារ និងបន្តសាងសង់រោងចំណតរថយន្តនៅខាងមុខបណ្ណាល័យ និងកែលម្អបញ្ចរបិទរូបថតខាងមុខព្រឹទ្ធសភា
- រៀបចំជួសជុលអគារនាយកដ្ឋាន ICT Studio និងបន្ទប់សម្រាប់អ្នកសារព័ត៌មាន
- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារបណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងប្រគល់សម្ភារៈជូនគណៈ-កម្មការទី១០ ព្រមទាំងអង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា សរុបចំនួន៥០៤គ្រឿង
- បានរៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភាឱ្យមានសោភ័ណភាពល្អ
- បានតាំងពិព័រណ៍រូបភាពចំនួន០៤លើក
- សហការជាមួយក្រុមហ៊ុនកំចាត់សត្វកណ្តៀរ និងសហការប្រចាំការម៉ាស៊ីនភ្លើង នៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យមើលការប្រើប្រាស់ទឹកភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកសរុបចំនួន៤៧លើក
- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុបចំនួន៥៣គ្រឿង។ បានUpload សេចក្តីជូនដំណឹង

| | |
|---|---|
| | ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន០៣ចំណងជើង។<br>+ ការងារផ្សេងៗ<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតវីដេអូ សម្រាប់បង្ហោះលើ Alert News ចំនួន ១៨៥ប្រធានបទ<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន៣១លើក<br>- បានចុះបញ្ជីសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ អ៊ុតគ្របសៀវភៅ បញ្ចូលសៀវភៅភាសាអង់គ្លេសក្នុងកម្មវិធី KOHA និងបញ្ជូនសៀវភៅដាក់នៅសាលអាន ព្រមទាំងជួសជុលឯកសារ និងសៀវភៅចាស់ៗ សរុបចំនួន៤០២ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច និងបញ្ចូលសៀវភៅតាមE-Library តាមបណ្តាញ Facebook សរុបចំនួន៦,៣៨០ក្បាល។ |

## II.ទិសដៅការងារខែតុលា ឆ្នាំ២០១៨

### ១.មុខងារនីតិកម្ម:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ (ថ្ងៃទី០៥ និងថ្ងៃទី១៧ ខែតុលា) និងសម័យប្រជុំពេញអង្គលើកទី២ ព្រឹទ្ធសភា នីតិកាលទី៤ (ថ្ងៃទី១១ និងថ្ងៃទី២៤ ខែតុលា) ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងរបាយការណ៍ចន្លោះសម័យប្រជុំលើកទី១ និងលើកទី២។

### ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មទៅខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ឧត្តរមានជ័យ ព្រះវិហារ កំពត និងខេត្តព្រះសីហនុ (ថ្ងៃទី០១-០៦ ខែតុលា ឆ្នាំ២០១៨)។

### ៣.មុខងារតំណាង :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភាប្រជុំជាមួយគណៈកម្មការរៀបចំបុណ្យជាតិ

-ត្រៀមរៀបចំប្រទីបព្រឹទ្ធសភា

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ការចូលរួមវេទិកា APPF នាខែមករា ឆ្នាំ២០១៩ នៅខេត្តសៀមរាប

-ការចូលរួមកិច្ចប្រជុំប្រធានសភាអាស៊ី-អឺរ៉ុប នៅប្រទេសតួកគី

-ការចូលរួមមហាសន្និបាត IPU និង ASGP នាខែតុលា នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស

-ត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវការក្នុងឱកាសខួបទី៦០ឆ្នាំ នៃទំនាក់ទំនងការទូត នាខែតុលា នៅសាធារណរដ្ឋប្រជាមានិតចិន

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-ត្រៀមអនុវត្តន៍កម្មវិធីជាមួយ(APF) នាពាក់កណ្តាលខែតុលា

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលនានា ដែលចាត់ចែងដោយវិទ្យាស្ថានសភាកម្ពុជា(PIC) ជាពិសេសវគ្គបណ្តុះបណ្តាលសភាតំបន់ នាដើមខែតុលា។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-បន្តតាមដានជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន

-រៀបចំជួសជុលកែលម្អ និងបន្តពង្រីកអគារសាលប្រជុំបណ្ណាល័យ

-បន្តកសាងអគាររបស់វិទ្យាស្ថានសភាកម្ពុជា(PIC) ការសាងសង់រោងចំណតរថយន្តនៅខាងមុខអាហារដ្ឋានព្រឹទ្ធសភា និងមុខសាលបណ្ណាល័យ ការកែលម្អផ្នែកខាងក្នុងអគារនាយកដ្ឋានICT (ជំហានទី២) ការជួសជុលបញ្ចរដាក់ តាំងរូបសកម្មភាពថ្នាក់ដឹកនាំ នៅខាងមុខព្រឹទ្ធសភា

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpageក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិក តាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល

ក្នុងនោះចូលអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-អនុវត្តគម្រោងបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមតម្រូវការថ្មី

-ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំគណៈកម្មការពិនិត្យ កែសម្រួលគោលការណ៍ ស្តីពីរបបសុំច្បាប់ ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តការសិក្សាអំពីការបង្កើតអគ្គនាយកដ្ឋានស្រាវជ្រាវ និងអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត ឆ្នាំ២០១៨

-ការស្នើសុំអាហារូបករណ៍សាកលវិទ្យាល័យបញ្ញាជាតិ អាស៊ីអឺរ៉ុប ភូមិន្ទភ្នំពេញ ជាតិគ្រប់គ្រង វេស្ទើនអន្តរជាតិ មេគង្គកម្ពុជា និងសាកលវិទ្យាល័យកម្ពុជា និងថ្នាក់ចំណេះដឹងទូទៅ និងភាសាអង់គ្លេសទូទៅសម្រាប់កូនៗរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៅសាលាប៊ែលធីអន្តរជាតិ

-ត្រៀមទទួលអាហារូបករណ៍ថៃខាងផ្នែកបច្ចេកវិទ្យាព័ត៌មានចំនួន១២នាក់ និងអាហារូបករណ៍ឥណ្ឌាខាងផ្នែកសន្តិសុខព័ត៌មានវិទ្យាចំនួន១២នាក់

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលៈវគ្គភាសាចិន (ខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៨) និងវគ្គMC (ខែតុលា ឆ្នាំ២០១៨ )

- សម្របសម្រួលបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០១នាក់ ទៅចូលរួមប្រឡងប្រជែងវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសលើកទី៥១ ក្រោមប្រធានបទ (Special Topic in Good Governance) នៅប្រទេសនូវែលសេឡង់

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់ក្រុមសមាជិកព្រឹទ្ធសភា អាណត្តិទី៤ ប្រចាំភូមិភាគទាំង៨

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ត្រៀមរៀបចំប្រារព្ធខួបអនុស្សាវរីយ៍គម្រប់២០ឆ្នាំ នៃការបង្កើតព្រឹទ្ធសភា (ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ )

-ត្រៀមលក្ខណៈចូលរួមពិធីបុណ្យសំខាន់ៗក្នុងខែតុលារួមមាន ពិធីបុណ្យភ្ជុំបិណ្ឌ ពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ ទិវាកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-ការរៀបចំទិវាមនុស្សចាស់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ការបើកប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ និងប្រាក់បៀវត្សរ៍ខែតុលា និងវិច្ឆិកា

-ការកែសម្រួលគោលការណ៍ហិរញ្ញវត្ថុថ្មីសម្រាប់អនុវត្តចាប់ពីឆ្នាំ២០១៩។

III.**សេចក្តីសន្និដ្ឋាន**

ខែកញ្ញានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំ និងចាត់ចែងការងារជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា លើសេវាទ្រទ្រង់មុខងារតាមដានការអនុវត្តច្បាប់ សវនាការរបស់គណៈកម្មការជំនាញជាមួយក្រសួងស្ថាប័ននានា និងការចុះបេសកកម្មទៅខេត្តកំពត បន្ទាយមានជ័យ ប៉ៃលិន មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង និងខេត្តក្រចេះ។ ដោយឡែកលើមុខងារតំណាង បានចុះតាមមូលដ្ឋាន ដើម្បីសិក្សាឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋ។ ចំពោះមុខងារអភិវឌ្ឍន៍ស្ថាប័ន ខិតខំបន្តជំរុញការអភិវឌ្ឍសំដៅពង្រីកហេដ្ឋារចនាសម្ព័ន្ធ ធនធានមធ្យោបាយ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗស្របតាមការរីកចម្រើននាពេលបច្ចុប្បន្ន។ ទន្ទឹមនេះ បានពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ តាមរយៈយន្តការទ្វេភាគី និងពហុភាគីក្នុងតំបន់ និងពិភពលោក។ ជាពិសេស ការចូលរួមប្រជុំមហាសន្និបាតអន្តរសភា(AIPA) លើកទី៣៩ នៅប្រទេសសិង្ហបុរី ប្រជុំវេទិកាប្រធានសភាអាស៊ី-អឺរុប (ASEP) លើកទី១០ នៅប្រទេសបែលហ្ស៊ិក ចូលរួមពិព័រណ៍អន្តរជាតិចិនភាគខាងលិចលើកទី១៧ នៅសាធារណរដ្ឋប្រជាមានិតចិន និងការចូលរួមវេទិកាសភា នៅប្រទេសស្រីលង្កា ឥណ្ឌូនេស៊ី និងសហព័ន្ធរុស្ស៊ី។

ក្នុងខែតុលាខាងមុខ មានការងារជាច្រើនគ្រោងសម្រាប់បេសកកម្មបំពេញមុខងារតំណាង និងតាមដានការអនុវត្តច្បាប់របស់គណៈកម្មការ និងក្រុមភូមិភាគនានា។ ជាពិសេស ព្រឹទ្ធសភាត្រូវបើកសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី៤ ព្រមទាំងត្រូវបំពេញកាតព្វកិច្ចអន្តរជាតិដ៏សំខាន់២ (កិច្ចប្រជុំនៅប្រទេសតួកគី និងទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន )។៚

ថ្ងៃ[illegible] ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

 អ៊ុំ_សារិទ្ធ